SeeBeyondBorders

គោលនយោបាយ

# គោលនយោបាយ ប្រាស្រ័យទាក់ទង

*Change begins with Education*

# TABLE OF CONTENTS

# មាតិកា

១. គោលបំណងនៃឯកសារ 3

២. គុណតម្លៃ 3

៣. និយមន័យ 4

៤. គោលនយោបាយ 5

៤.១. គោលនយោបាយគ្រប់គ្រងប្រាស្រ័យទាក់ទងទាំងអស់រួមមាន៖ 5

៤.២. ប្រាស្រ័យទាក់ទងទីផ្សារផ្សព្វផ្សាយចេញទៅក្រៅ 6

៤.៣ ការឆ្លើយតបទៅនឹងការស្នើសុំពត៌មាន 9

៤.៤ ការឆ្លើយសំណួរពីសារពត៌មាន 9

៤.៥ ប្រាស្រ័យទាក់ទងទាក់ទងជាមួយអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត 10

៤.៦ របាយការណ៍ប្រចាំឆ្នាំ 10

៤.៧ របាយការណ៍ហិរញ្ញវត្ថុ 11

៤.៨ អ្វីដែលរៀនសូត្របាន 11

៥. ការគ្រប់គ្រងគោលនយោបាយ 12

# គោលនយោបាយប្រាស្រ័យទាក់ទង

## ១. គោលបំណងនៃឯកសារ

ឯកសារនេះផ្តល់នូវទិដ្ឋភាពទូទៅនៃការប្រាស្រ័យទាក់ទងផ្សេងៗ ដែលធ្វើឡើងដោយអង្គការទស្សនៈឥតព្រំដែន និងសំណុំនៃគោលការណ៍ណែនាំជាបន្តបន្ទាប់សម្រាប់បុគ្គលិក និងអ្នកស្ម័គ្រចិត្ត។ បុគ្គលិក និងអ្នកស្ម័គ្រចិត្តគ្រប់រូប ដែលចូលរួមជាមួយអង្គការទស្សនៈឥតព្រំដែន ត្រូវបានរំពឹងថានឹងប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំការប្រាស្រ័យទាក់ទងទាំងនេះ។

គោលបំណងនៃគោលនយោបាយប្រាស្រ័យទាក់ទងនេះគឺដើម្បី៖

- ធានាថាអង្គការទស្សនៈឥតព្រំដែន ប្រកាន់ខ្ជាប់នូវតម្រូវការបទប្បញ្ញត្តិសំខាន់ៗ និងមានស្តង់ដារវិស័យនេះ។
- ធានាថាបុគ្គលិក និងអ្នកស្ម័គ្រចិត្តអង្គការទស្សនៈឥតព្រំដែនត្រូវបានជូនដំណឹងយ៉ាងពេញលេញ អំពីគោលនយោបាយសំខាន់ៗរបស់អង្គការ ដែលកំណត់ឥរិយាបថសមស្រប និងឥរិយាបថដែលរំពឹងទុក ជាពិសេសគោលនយោបាយការពារកុមារ និងជនងាយរងគ្រោះ។
- ធានាថារាល់ការប្រាស្រ័យទាក់ទងខាងក្រៅឆ្លុះបញ្ចាំងពីផែនការយុទ្ធសាស្រ្តរបស់អង្គការទស្សនៈឥតព្រំដែន ២០២១-២០២៦ ផែនការប្រតិបត្តិការ និងគុណតម្លៃស្នូល។
- ធានាថាមានក្របខ័ណ្ឌសមស្រប ដែលសិទ្ធិឯកជនភាពរបស់កុមារ គ្រួសារ គ្រូបង្រៀន នាយកសាលា និងមនុស្សផ្សេងទៀតទាំងអស់ ដែលអង្គការកំពុងធ្វើការជាមួយត្រូវបានពិចារណា និងគោរព។
- ធានាថាមានក្របខ័ណ្ឌសមស្របមួយ ដែលសិទ្ធឯកជនភាពរបស់ម្ចាស់ជំនួយ ទាំងបច្ចុប្បន្ន ឬអតីតកាល ឬម្ចាស់ជំនួយដែលមានសក្តានុពលនាពេលអនាគត ដែលយើងទាក់ទងជាមួយ នឹងត្រូវបានគេពិចារណា និងគោរព។
- ធានាថាមានក្របខ័ណ្ឌសមស្របមួយដែលសិទ្ធិឯកជនភាពរបស់បុគ្គលិកអង្គការទស្សនៈឥតព្រំដែនបច្ចុប្បន្ន និងអតីតកាលត្រូវបានពិចារណា និងគោរព។

ឯកសារនេះគួរតែត្រូវបានអានដោយភ្ជាប់ជាមួយផែនការយុទ្ធសាស្រ្តឆ្នាំ២០២១-២០២៦ Strategic Plan 2021-2026 របស់អង្គការ ដែលគ្រប់គ្រងគោលបំណងអភិវឌ្ឍន៍របស់អង្គការទស្សនៈឥតព្រំដែន និងរបៀបដែលអនុវត្តកិច្ចការទាំងនោះ។ វាក៏គួរតែត្រូវបានអានដោយភ្ជាប់ជាមួយគោលនយោបាយរបស់អង្គការ និងកញ្ចប់ឧបករណ៍រួមទាំង Images Policy, Fundraising Policy, Child and Vulnerable People Protection Policy, Development Policy, Privacy and Cookies Policy និង Ethical Decision Making Framework for Communications (កញ្ចប់ឧបករណ៍)។

## ២. គុណតម្លៃ

ទស្សនវិជ្ជាអភិវឌ្ឍន៍អង្គការទស្សនៈឥតព្រំដែន បានកំណត់គោលការណ៍គ្រឹះសម្រាប់របៀបគ្រប់គ្រងរាល់ទិដ្ឋភាពនៃការងាររបស់យើង។ គុណតម្លៃដែលមានចែងក្នុងគោលនយោបាយអភិវឌ្ឍន៍បញ្ជាក់ពីសកម្មភាពទាំងអស់ទាំងខាងក្នុង និងខាងក្រៅរបស់អង្គការ។ នេះរាប់បញ្ចូលទាំងរបៀបដែលយើងធ្វើការជាមួយគ្នា ហើយសំខាន់ទៀតនោះគឺរបៀបដែលយើងចូលរួមជាមួយអ្នកពាក់ព័ន្ធខាងក្រៅទាំងអស់។

ចំនុចសំខាន់នៃគោលនយោបាយនេះគឺជាគុណតម្លៃដែលមាននៅក្នុងផែនការយុទ្ធសាស្រ្ត ព្រោះទាំងនេះក៏បញ្ជាក់ពីរបៀបដែលការប្រាស្រ័យទាក់ទងនឹងត្រូវបានអនុវត្តផងដែរ។ សម្រាប់ជាឯកសារយោង គុណតម្លៃទាំងនេះត្រូវបានបញ្ជាក់ឡើងវិញនៅខាងក្រោម៖

**អ្នកផ្លាស់ប្រែ៖** អាទិភាពធំបំផុតរបស់យើងគឺបង្កើតការផ្លាស់ប្តូរជាវិជ្ជមានជាទ្រង់ទ្រាយធំ និងប្រកបដោយនិរន្តរភាពនៅកម្ពុជា។ យើង មិនគ្រាន់តែជួយសហគមន៍មួយ ឬពីរប៉ុណ្ណោះទេ យើងកំពុងធ្វើការឆ្ពោះទៅរកការផ្លាស់ប្តូរជាប្រព័ន្ធ និងនិរន្តរភាពទ្រង់ទ្រាយធំ ដូច្នេះ នៅថ្ងៃណាមួយជំនួយពីអង្គការទស្សនៈឥតព្រំដែនដែលមានក្នុងពេលបច្ចុប្បន្ននឹងលែងត្រូវការទៀតហើយ។

**សមត្ថភាព៖** គ្រប់កម្មវិធីរបស់យើងទាំងអស់ត្រូវបានគាំទ្រដោយចំណេះដឹង និងបទពិសោធន៍។ ក្រុមរបស់យើងត្រូវបានបង្កើតឡើង ដោយអ្នកជំនាញដែលបានទទួលការបណ្តុះបណ្តាលច្បាស់លាស់ ដែលបំពេញការងារប្រកបដោយសមត្ថភាព និងជំនាញ។ យើង តែងតែធ្វើការដើម្បីចែករំលែក និងកសាងចំណេះដឹង រៀនពីបទពិសោធន៍ និងជំរុញគំនិតនៃការផ្លោះប្តូរចំណេះដឹងទៅវិញទៅមក។

**សុចរិតភាព៖** យើងតែងតែមានតម្លាភាព និងចាត់ទុកកំហុសជាឱកាសដើម្បីរៀនសូត្រ។ យើងតែងតែប្រឹងប្រែងដើម្បីភាពស្មោះត្រង់ និងដើម្បីធានាថាវាជាចក្ខុវិស័យរួមគ្នារបស់យើងតែមួយគត់ ដែលជំរុញការងាររបស់យើង។

**សេចក្តីក្លាហាន៖** វាមិនងាយស្រួលទេក្នុងការប្រជែងនឹងទស្សនៈកំពុងមានការប្រកាន់ខ្ជាប់ស្រាប់។ ប៉ុន្តែដើម្បីកសាងអនាគតដ៏ប្រសើរសម្រាប់កុមារកម្ពុជា បុគ្គលិក ដៃគូរបស់យើង និងសហគមន៍ដែលយើងធ្វើការជាមួយធ្វើ សកម្មភាពដោយភាពក្លាហានជារៀងរាល់ថ្ងៃ ដើម្បីបន្តដំណើរប្រឈមមុខនឹងការលំបាក។

**ការគោរព៖** សកម្មភាពរបស់យើងតែងតែបង្កើតឡើងដោយផ្តល់ការគោរពចំពោះគ្រូបង្រៀន សិស្ស និងសមាជិកសហគមន៍ ដែលយើងធ្វើការជាមួយសមាជិកក្រុម ម្ចាស់ជំនួយ និងអ្នកគាំទ្ររបស់យើង។ យើងទទួលស្គាល់អំណាចដែលយើងមានតាមរយៈតំណាងនៃសហគមន៍ដែលយើងធ្វើការជាមួយតាមរបៀបស្មោះត្រង់ គោរព និងយល់ស្របពេញលេញប៉ុណ្ណោះ។

## ៣. និយមន័យ

**ការប្រាស្រ័យទាក់ទង៖** ការប្រាស្រ័យទាក់ទងគ្របដណ្តប់គ្រប់ទម្រង់នៃការទំនាក់ទំនងរវាងអ្នកតំណាងអង្គការទស្សនៈឥតព្រំដែន និងអ្នកផ្សេងទៀត រួមទាំង ប៉ុន្តែមិនកំណត់ចំពោះ៖ ម្ចាស់ជំនួយ ដៃគូ អ្នកគាំទ្រ បុគ្គលិក អ្នកស្ម័គ្រចិត្ត អ្នកទទួលជំនួយទាំងអស់ ពីកម្មវិធីអង្គការទស្សនៈឥតព្រំដែន និងសាធារណជនទូទៅ។

**មធ្យោបាយប្រាស្រ័យទាក់ទង៖** ការចែករំលែកព័ត៌មាន ដោយប្រើមធ្យោបាយប្រាស្រ័យទាក់ទងខាងក្រោម បង្កើតបានជាទម្រង់ប្រាស្រ័យទាក់ទង៖

១. ទស្សនីយភាពជារូបថត វីដេអូ
២. ពាក្យសំដី ការសន្ទនា រួមទាំងពេលចូលរួមកិច្ចប្រជុំ និងការសន្ទនាតាមទូរស័ព្ទ។
៣. ប្រព័ន្ធឌីជីថល អ៊ីមែល បទបង្ហាញ គេហទំព័រ ប្រព័ន្ធផ្សព្វផ្សាយសង្គម រួមទាំង Facebook, Instagram, Twitter, WordPress, Mailchimp, YouTube និង LinkedIn។
៤. សំណេរ ការឆ្លើយឆ្លងផ្លូវការ ខិត្តប័ណ្ណ ការផ្សាយពាណិជ្ជកម្ម ការចេញផ្សាយពត៌មាន អត្ថបទពត៌មាន បទបង្ហាញ និងទម្រង់ផ្សេងៗទៀតនៃការផ្សព្វផ្សាយពត៌មាន។

**អ្នកប្រាស្រ័យទាក់ទង៖** បុគ្គលដែលចូលរួមក្នុងការប្រាស្រ័យទាក់ទងក្នុងទម្រង់ណាមួយជាមួយអង្គការទស្សនៈឥតព្រំដែន ឬភាគីពាក់ព័ន្ធរបស់អង្គការ។

**ការប្រាស្រ័យទាក់ទងផ្ទៃក្នុង៖** ទម្រង់នៃការប្រាស្រ័យទាក់ទងទាំងអស់ដែលកើតឡើងរវាងតំណាងរបស់អង្គការទស្សនៈឥតព្រំដែន (បុគ្គលិក អ្នកស្ម័គ្រចិត្ត ក្រុមប្រឹក្សាភិបាល អ្នកប្រឹក្សាយោបល់) ដែលធ្វើឡើងជាផ្នែកនៃការប្រាស្រ័យទាក់ទងប្រចាំថ្ងៃជាមួយគ្នាទៅវិញទៅមក ហើយមិនត្រូវបានចែករំលែកជាមួយអ្នកពាក់ព័ន្ធខាងក្រៅណាមួយឡើយ។

**ការប្រាស្រ័យទាក់ទងខាងក្រៅ៖** ទម្រង់នៃការប្រាស្រ័យទាក់ទងណាមួយដែលធ្វើឡើងដោយតំណាងរង្គការទស្សនៈឥតព្រំដែន ទៅកាន់បុគ្គល ឬក្រុមខាងក្រៅ និងសាធារណៈជនទូទៅ។

**ព័ត៌មានផ្ទាល់ខ្លួន៖** ព័ត៌មានទាក់ទងនឹងជីវិតផ្ទាល់ខ្លួនរបស់អ្នកតំណាងអង្គការទស្សនៈឥតព្រំដែន ដូចជាព័ត៌មានលម្អិតទាក់ទងនឹងគ្រួសារ មិត្តភក្តិ ជំនឿនយោបាយ ឬសាសនា ទស្សនៈ និងមតិយោបល់លើបញ្ហាដែលនៅក្រៅវិសាលភាពការងាររបស់អង្គការទស្សនៈឥតព្រំដែន។ នេះក៏អាចរួមបញ្ចូលព័ត៌មានផ្សេងទៀតដូចជាព័ត៌មានលម្អិតគណនីធនាគារ ឬព័ត៌មានលម្អិតប្រាស្រ័យទាក់ទងក្នុងករណីម្ចាស់ជំនួយ ឬទិន្នន័យដែលអនុញ្ញាតឱ្យកំណត់អត្តសញ្ញាណបុគ្គល។

**ព័ត៌មានវិជ្ជាជីវៈ** ព័ត៌មានដែលទាក់ទងដោយផ្ទាល់ទៅនឹងកិច្ចប្រតិបត្តិការ និងសកម្មភាពដែលធ្វើឡើងដោយអង្គការទស្សនៈឥតព្រំដែន ឬត្រូវបានបង្កើតឡើងដោយកិច្ចប្រតិបត្តិការ និងសកម្មភាពទាំងនោះ។

**បទប្បញ្ញត្តិអាជ្ញាធរ៖** អង្គការទស្សនៈឥតព្រំដែនត្រូវរាយការណ៍ទៅកាន់រដ្ឋាភិបាល និងអង្គការឯករាជ្យមួយចំនួនដោយស្ម័គ្រចិត្ត ឬដើម្បីបំពេញតាមលក្ខណៈវិនិច្ឆ័យការទទួលស្គាល់ជាក់លាក់។

## ៤. គោលនយោបាយ

អង្គការទស្សនៈឥតព្រំដែនលើកទឹកចិត្តឱ្យមានការប្រាស្រ័យទាក់ទងដោយសេរីនៅគ្រប់ទិដ្ឋភាពទាំងអស់នៃសកម្មភាពរបស់ខ្លួន និងស្វែងរកសាធារណជនបន្ថែមដើម្បីបញ្ចេញមតិ Blog Tweet ឬប្រាស្រ័យទាក់ទងតាមមធ្យោបាយផ្សេងៗ អំពីការងារអង្គការទស្សនៈឥតព្រំដែនក្នុងទម្រង់ណាមួយ។ ទោះជាយ៉ាងណាក៏ដោយ អង្គការទស្សនៈឥតព្រំដែន ត្រូវប្រាកដថាការប្រាស្រ័យទាក់ទងក្នុងបរិបទ និងចេតនាសមស្រប ព្រមទាំងមានភាពស្មោះត្រង់ ត្រឹមត្រូវ និងទាន់ពេលវេលា។ ដូច្នេះ គ្មានការបោះពុម្ពផ្សព្វផ្សាយក្នុងនាម ឬតំណាងឱ្យអង្គការទស្សនៈឥតព្រំដែន ដោយគ្មានការអនុញ្ញាតជាមុនពីបុគ្គលិកបង្គោលឡើយ។ អង្គការទស្សនៈឥតព្រំដែនធ្វើការទាក់ទងជាភាសាអង់គ្លេសជាចម្បង ហើយម្តងម្កាលមានខ្លឹមសារជាភាសាខ្មែរ ដូច្នេះបុគ្គលិកបង្គោលដែលត្រូវពិនិត្យ គឺខុសគ្នាទៅតាមភាសាដែលប្រើ។ បុគ្គលិកបង្គោលសម្រាប់ការប្រាស្រ័យទាក់ទងជាភាសាអង់គ្លេសគឺ CEO International Operations, Chief Executive Australia ឬ Communications Mentor។ បុគ្គលិកបង្គោលប្រាស្រ័យទាក់ទងជាភាសាខ្មែរគឺ អ្នកគ្រប់គ្រងប្រទេស អ្នកគ្រប់គ្រងផ្នែកអប់រំបច្ចេកទេស ឬអ្នកសម្របសម្រួលប្រាស្រ័យទាក់ទង។

ចំណុចនៃគោលនយោបាយខាងក្រោមអនុវត្តចំពោះប្រាស្រ័យទាក់ទងទាំងអស់។

### ៤.១. គោលនយោបាយគ្រប់គ្រងប្រាស្រ័យទាក់ទងទាំងអស់រួមមាន៖

ក. ***តម្លាភាព និងភាពត្រឹមត្រូវ៖*** អ្នកផ្តួចផ្តើមប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ ត្រូវចាត់វិធានការសមហេតុផលដើម្បីប្រាកដថាសាររបស់ពួកគេមិនថាក្នុងទម្រង់ទំនាក់ទំនងណាក៏ដោយតែងតែត្រឹមត្រូវ និងមានតម្លាភាព។

ខ. ***ទាន់ពេលវេលា និងសកម្ម៖*** ការប្រាស្រ័យទាក់ទងជាមួយភាគីពាក់ព័ន្ធទាន់ពេលវេលា ដោយធានាថាព័ត៌មានពាក់ព័ន្ធសំខាន់ៗត្រូវបានបញ្ជូនក្នុងចន្លោះពេលសមស្របដោយបានគិតពិចារណាពីផលប៉ះពាល់ ឬចំណាប់អារម្មណ៍របស់ភាគីនោះ។ ដូចគ្នានេះ

ដែរប្រសិនបើអង្គការទស្សនៈឥតព្រំដែនទទួលបានពត៌មានសំខាន់ៗ យើងនឹងធ្វើការចែករំលែកវាយ៉ាងសកម្មជាមួយភាគីពាក់ព័ន្ធ។

គ. ***ព័ត៌មានរសើប និងការទទួលព័ត៌មាន៖*** ទម្រង់នៃការប្រាស្រ័យទាក់ទង និងមធ្យោបាយបញ្ជូន ផ្អែកទៅលើប្រព័ន្ធផ្សព្វផ្សាយដែលត្រូវបានប្រើ។ ព័ត៌មានខ្លះអាចសមស្របសម្រាប់ព្រឹត្តិបត្រព័ត៌មានប្រចាំ ប៉ុន្តែព័ត៌មានផ្សេងទៀត ដែលងាយប៉ះពាល់អារម្មណ៍ត្រូវការប្រាស្រ័យទាក់ទងបែបឯកជនជាមួយបុគ្គលជាក់លាក់។ នៅពេលដោះស្រាយបញ្ហាជាក់លាក់ណាមួយ ឬបើមានអ្វីមិនច្បាស់លាស់ សូមទៅពីភាក្សាជាមួយបុគ្គលិកបង្គោលសម្រាប់ជំនួយ ឬការណែនាំ។

ឃ. ***ការគោរព៖*** រាល់ការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ បុគ្គលិក និងអ្នកស្ម័គ្រចិត្ត អង្គការទស្សនៈឥតព្រំដែន តម្រូវឱ្យប្រព្រឹត្តចំពោះភាគីនោះ ដោយការគោរពបំផុតចំពោះសេចក្តីថ្លៃថ្នូរ តម្លៃ ប្រវត្តិសាស្ត្រ សាសនា និងវប្បធម៌របស់ពួកគេ។ ខណៈពេលដែលធ្វើការឱ្យអង្គការ បុគ្គលិក និងអ្នកស្ម័គ្រចិត្តអង្គការទស្សនៈឥតព្រំដែន ត្រូវតែដើរតួជាអ្នកតំណាងអង្គការទាំងក្នុង និងក្រៅកន្លែងធ្វើការ ហើយយកចិត្តទុកដាក់ដើម្បីលើកតម្កើងគុណតម្លៃរបស់អង្គការដោយបង្ហាញការគោរព និងភាពថ្លៃថ្នូរ ហើយចាត់វិធានការដែលចាំបាច់ជៀសវាងការប្រមាថដល់អ្នកដទៃក្នុងគ្រប់ប្រាស្រ័យទាក់ទងទាំងអស់។

ង. ***ឯកជនភាព៖*** យោងតាមគោលនយោបាយឯកជនភាពរបស់អង្គការទស្សនៈឥតព្រំដែន អង្គការទស្សនៈឥតព្រំដែន នឹងគោរពភាពឯកជនរបស់បុគ្គលគ្រប់រូបគ្រប់ពេលវេលា ហើយនឹងមិនផ្សព្វផ្សាយ ឬប្រាស្រ័យទាក់ទងព័ត៌មានផ្ទាល់ខ្លួនអំពីបុគ្គលណាម្នាក់ដោយគ្មានការអនុញ្ញាតពីគាត់ និងដោយមិនមានគាត់ជាអ្នកផ្តល់ ព័ត៌មានផ្ទាល់ខ្លួនដោយខ្លួនឯងនោះទេ។ ពេលខ្លះយើងមិនច្បាស់ថាតើបុគ្គលនោះមានការយល់ដឹងពេញលេញអំពី ការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់គាត់ ឬទេ នៅពេលដែលគាត់ផ្តល់ការអនុញ្ញាតមកខាងយើង។ ក្នុងករណីបែបនេះ គន្លឹះគឺការវាយតម្លៃថាតើព័ត៌មាននោះ នៅពេលផ្សព្វផ្សាយអាចបង្កគ្រោះថ្នាក់ផ្ទាល់ខ្លួន ការលំបាក ឬប៉ះពាល់កេរ្តិ៍ឈ្មោះដល់បុគ្គលដែលពាក់ព័ន្ធដែរឬទេ។

ច. ***ព័ត៌មានគួរ ឬមិនគួរយកទៅធ្វើការប្រាស្រ័យទាក់ទង៖*** បន្ថែមពីលើព័ត៌មានផ្ទាល់ខ្លួនដូចដែលបានលើកឡើងខាងលើ មិនត្រូវប្រាស្រ័យទាក់ទងនូវព័ត៌មាន ដែលមានបំណងបង្កគ្រោះថ្នាក់ ព្យាបាទ បង្ខូចកេរ្តិ៍ឈ្មោះ ឬព័ត៌មានដែលគ្មានភស្តុតាងឡើយ។ គ្រប់ករណី រាល់ការប្រាស្រ័យទាក់ទងនឹងផ្តោតលើសកម្មភាពរបស់អង្គការទស្សនៈឥតព្រំដែនស្របតាមទស្សនវិជ្ជា និងគុណតម្លៃរបស់អង្គការដោយប្រកាន់ខ្ជាប់នូវប្រធានបទដែលទាក់ទង នឹងគោលដៅ និងគោលបំណងរបស់អង្គការ។

ឆ. ***កាលវិភាគប្រាស្រ័យទាក់ទង៖*** ការប្រាស្រ័យទាក់ទង នឹងប្រព្រឹត្តទៅតាមកាលវិភាគដែលបានកំណត់ទុកជាមុន។ នេះរាប់ទាំងការរាយការណ៍ដល់ម្ចាស់ជំនួយអំពីគម្រោង ដែលពួកគេបានរួមចំណែកព ត៌មានហិរញ្ញវត្ថុក្នុងទម្រង់នៃរបាយការណ៍ប្រចាំឆ្នាំ ប្រជុំបុគ្គលិក នាយកប្រតិបត្តិ គណៈកម្មាធិការរៃអង្គាសប្រាក់ ឬក្រុមប្រឹក្សាភិបាល ឬព្រឹត្តិបត្រព័ត៌មាន។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើមានកិច្ចបន្ទាន់ យើងនឹងមិនរង់ចាំតាមពេលវេលាដែលបានកំណត់នោះទេ ហើយបុគ្គលបង្គោល នឹងសម្រេចចិត្តថាពេលណាត្រូវចែករំលែកព័ត៌មាននោះ។

## ៤.២. ប្រាស្រ័យទាក់ទងនឹងផ្សារផ្សព្វផ្សាយចេញទៅក្រៅ

ភាពទៀងទាត់និងស្មោះត្រង់គឺតម្រូវឱ្យមាននៅក្នុងខ្លឹមសារ ដែលយើងចែករំលែកជាមួយមនុស្សដែលពាក់ព័ន្ធនឹងសកម្មភាពរបស់អង្គការទស្សនៈឥតព្រំដែន។ ដូចនេះជាតុសំខាន់ៗនៃការផ្សព្វផ្សាយមានដូចជារូបភាព ដែលត្រូវបានពិនិត្យ និងអនុម័តដោយបុគ្គលបង្គោលសម្រេចចិត្តថាតើវាពាក់ព័ន្ធនឹងស្ថានភាព ឬអត់។ ក្នុងគ្រប់ករណីទាំងអស់ សម្ភារៈទីផ្សាររួមបញ្ចូល៖

ក. ***រូបភាពប្រជាជនក្នុងតំបន់៖*** អង្គការទស្សនៈឥតព្រំដែននឹងធានាថា ការប្រើប្រាស់រូបភាព និងសារដែលបង្ហាញពីស្ត្រី និងបុរស កុមារា និងកុមារី ក្នុងការប្រាស្រ័យទាក់ទងដោយមានការគោរពសេចក្តីថ្លៃថ្នូរ តម្លៃ ប្រវត្តិសាស្ត្រ សាសនា និងវប្បធម៌របស់បុគ្គលដែលបានបង្ហាញ។ សូមមើលបញ្ញត្តិ ៤.២គ សម្រាប់ព័ត៌មានបន្ថែមស្តីពីការបង្ហាញរូបភាព។

ខ. **ការអនុវត្តភាពស្មោះត្រង់ និងតម្លាភាព៖** រូបភាព និងសារត្រូវបង្ហាញដោយស្មោះត្រង់ពីភាពចម្រុះនៃប្រជាជនក្នុងតំបន់ រួមទាំងអាយុ ពិការភាព និងក្រុមដែលងាយរងគ្រោះផ្សេងៗទៀត។ រូបភាព និងសារនឹងបង្ហាញដោយស្មោះត្រង់នូវបរិបទ និងភាពចម្រុះនៃស្ថានភាពដែលប្រជាជនក្នុងតំបន់រស់នៅ។

គ. **ការអនុវត្តឯកជនភាព៖** បុគ្គលសំខាន់ៗនៅក្នុងរូបភាពនឹងត្រូវបានជូនដំណឹងអំពីគោលបំណងដែលប្រើប្រាស់រូបភាព និងការសុំអនុញ្ញាតពីពួកគេ ដោយអនុលោមតាមគោលនយោបាយរូបភាពដែលជាគោលនយោបាយដាច់ដោយឡែកមួយ ហើយទាក់ទងនឹងគោលនយោបាយប្រាស្រ័យទាក់ទង និងការការពារជនងាយរងគ្រោះ និងតភ្ជាប់ជាមួយនឹងគោលនយោបាយក្រមសីលធម៌របស់អង្គការទស្សនៈឥតព្រំដែនផងដែរ។ ដូចដែលបានកំណត់នៅក្នុងគោលនយោបាយរូបភាព ការយកចិត្តទុកដាក់នឹងត្រូវបានធ្វើឡើងដើម្បីធានាថាការកំណត់អត្តសញ្ញាណ ឬការប្រើប្រាស់រូបភាពរបស់បុគ្គលក្នុងតំបន់នឹងមិនបង្កគ្រោះថ្នាក់ដល់ពួកគេនៅពេលធ្វើការបង្ហាញនោះឡើយ។

ឃ. **បរិយាបន្ន និងបង្ហាញរូបភាព៖** ក្នុងគ្រប់ករណីទាំងអស់អង្គការទស្សនៈឥតព្រំដែនធានាថាប្រើប្រាស់ខ្លឹមសារ និងរូបភាពអនុលោមតាមការណែនាំដែលមានចែងក្នុងគោលនយោបាយបរិយាបន្ន ដោយធានាឱ្យមានការតំណាងដោយយុត្តិធម៌ និងតម្លាភាពជុំវិញប្រធានបទផ្សេងៗគ្នា។

ង. **រក្សាសិទ្ធិ៖** ប្រភពដើមនៃរូបភាពដែលបានប្រើនឹងត្រូវបានគេស្គាល់ ហើយការអនុញ្ញាតចាំបាច់ណាមួយរួមទាំងការចេញផ្សាយការរក្សាសិទ្ធិនឹងត្រូវធ្វើឡើង។

ច. **បទប្បញ្ញត្តិការពារទិន្នន័យទូទៅ៖** អង្គការទស្សនៈឥតព្រំដែនអនុលោមតាមបទប្បញ្ញត្តិការពារទិន្នន័យទូទៅ (២០១៨) និងប្រាស្រ័យទាក់ទងជាមួយអ្នកគាំទ្រដោយផ្អែកលើច្បាប់ ដូចដែលមានចែងក្នុងគោលនយោបាយឯកជនភាពរបស់យើង ជាធម្មតានៅពេលទទួលបានការអនុញ្ញាតច្បាស់លាស់ផ្តល់ដោយសមីជន។

ឆ. **ក្របខណ្ឌក្រមសីលធម៌នៃការសម្រេចចិត្ត៖** ក្នុងគ្រប់ករណីអង្គការទស្សនៈឥតព្រំដែននឹងធានាថារូបភាព និងការសារទាំងអស់គឺអនុលោមតាមគោលនយោបាយរូបភាព និងក្របខណ្ឌក្រមសីលធម៌នៃការសម្រេចចិត្ត ព្រមទាំងគោលការណ៍ណែនាំ និងដំណើរការអនុម័តពាក់ព័ន្ធដែលមានចែងក្នុងគោលនយោបាយនីមួយៗ។

ជ. **ការការពារកុមារ និងជនងាយរងគ្រោះ៖** ក្នុងគ្រប់ករណីទាំងអស់ អង្គការទស្សនៈឥតព្រំដែន នឹងធានាថាការប្រើប្រាស់ខ្លឹមសារ និងរូបភាពអនុលោមតាមបញ្ញត្តិទី ៩ នៃគោលនយោបាយការពារកុមារ និងជនងាយរងគ្រោះ ដែលបានចែងថា:

ដើម្បីការពារកុមារ យុវជន និងជនងាយរងគ្រោះដែលពាក់ព័ន្ធ នៅពេលថតរូប ឬថតសកម្មភាពកុមារ/ជនងាយរងគ្រោះ ឬប្រើប្រាស់រូបភាពរបស់កុមារក្នុងគោលបំណងសម្រាប់ទំនាក់ទំនង និងការងារអង្គការទស្សនៈឥតព្រំដែននឹងធានាថា៖

- ប្រពៃណី ឬការរិតត្បិតក្នុងស្រុកចំពោះការផលិតរូបថតបុគ្គល ត្រូវបានអនុលោម មុនពេលថត ឬវីដេអូ។
- សេចក្តីយល់ព្រមផ្ទាល់មាត់ និងឯកសារយល់ព្រម (ជាលាយលក្ខណ៍អក្សរ) ពីឪពុកម្តាយ ឬអាណាព្យាបាលកុមារមុនពេលថតរូប ឬវីដេអូ និងពន្យល់ពីគោលបំណងនៃការប្រើប្រាស់រូបភាព និងវីដេអូនេះ។ ដំណើរការនេះត្រូវធ្វើឡើងជាភាសាខ្មែរ។
- រាល់ការផ្សព្វផ្សាយត្រូវបង្ហាញអំពីភាពថ្លៃថ្នូរ និងគោរព មិនមែនស្ថានភាព ឬឥរិយាបទងាយរងគ្រោះ តោកយ៉ាករបស់កុមារឡើយ។ កុមារត្រូវមានសម្លៀកបំពាក់សមរម្យ និងមិនបង្ហាញពីភាពទាក់ទាញផ្លូវភេទឡើយ។
- រូបភាពគឺបង្ហាញពីភាពស្មោះត្រង់ និងបង្ហាញស្ថានភាព និងបរិបទជាក់ស្តែង។

- ឈ្មោះឯកសារ ទិន្នន័យយោង និងសេចក្តីបរិយាយឯកសារទាំងឡាយ មិនបានបង្ហាញឱ្យដឹងអំពីព័ត៌មានសម្គាល់អត្តសញ្ញាណកុមារ ឬជនរងគ្រោះ នៅពេលផ្ញើរូបភាពតាមសារអេឡិចត្រូនិក ឬបង្ហាញរូបនេះជាសាធារណៈក្នុងទម្រង់ណាមួយឡើយ។ នេះរាប់បញ្ចូលទាំងឈ្មោះពេញ ឈ្មោះសាលា ព័ត៌មានលម្អិតអំពីទីតាំងភូមិសាស្ត្រ និងព័ត៌មានផ្សេងទៀត ដែលអាចឱ្យភាគីទីបីឈានទៅកំណត់អត្តសញ្ញាណ និងចូលដល់ទីតាំងជននោះ តាមរយៈការផ្សព្វផ្សាយរបស់អង្គការទស្សនៈឥតព្រំដែន។ ចាត់តាំងជ្រើសរើសបុគ្គលិកម្នាក់របស់អង្គការទស្សនៈឥតព្រំដែន ឱ្យអាចចូលត្រួតពិនិត្យបណ្ណាល័យរូបថត និងឯកសារអនុញ្ញាតឱ្យថតរូប ដើម្បីប្រាកដថា មានឯកសារបញ្ជាក់ការអនុញ្ញាតត្រឹមត្រូវ មុននឹងធ្វើការផ្សព្វផ្សាយ។
- បុគ្គលិក អ្នកស្ម័គ្រចិត្ត និងអ្នកទស្សនាទាំងអស់ត្រូវអាន និងយល់ពីគោលនយោបាយរូបភាព ហើយចុះហត្ថលេខា និងប្រកាន់ខ្ជាប់នូវក្រមសីលធម៌របស់អង្គការទស្សនៈឥតព្រំដែន ។
- បុគ្គលិក និងអ្នកស្ម័គ្រចិត្តទាំងអស់ទទួលការបណ្តុះបណ្តាលលើគោលនយោបាយនេះ (រួមជាមួយនឹងការបណ្តុះបណ្តាលលើគោលនយោបាយការពារកុមារ និងជនងាយរងគ្រោះ និងបរិយាបន្ន) និងគោលការណ៍ណែនាំ (ជាភាសាខ្មែរ និងអង់គ្លេស) អំពីរបៀបទទួលបានការអនុញ្ញាតយល់ព្រម កត់ត្រា និងរក្សាទុករូបភាព និងរបៀបដែលរូបភាពផ្សព្វផ្សាយបាន។
- ចាត់តាំងបុគ្គលិកម្នាក់ដើម្បីរក្សាការរក្សារូបភាព និងឯកសារអនុញ្ញាត។
- អ្នកថតរូបជំនាញចុះហត្ថលេខា និងប្រកាន់ខ្ជាប់នូវក្រមសីលធម៌របស់អង្គការទស្សនៈឥតព្រំដែន។
- អ្នកថតរូបត្រូវបានអមដំណើរ និងគ្មានសិទ្ធិចូលដោយផ្ទាល់ទៅជួបកុមារម្នាក់ៗនោះទេ។
- បុគ្គល ឬអង្គការណាមួយដែលធ្វើការជាមួយអង្គការទស្សនៈឥតព្រំដែន លើកម្មវិធីដែលមានមូលដ្ឋាននៅសាលារៀន ត្រូវដឹងពីគោលនយោបាយរូបភាព និងតម្រូវឱ្យចុះហត្ថលេខា និងប្រកាន់ខ្ជាប់នូវក្រមសីលធម៌អង្គការទស្សនៈឥតព្រំដែន។
- គ្មានការផ្សព្វផ្សាយភ្ជាប់ព័ត៌មានផ្ទាល់ខ្លួន ដែលអាចកំណត់អត្តសញ្ញាណរបស់កុមារ និងជនងាយរងគ្រោះ ដែលអមជាមួយរូបថតដែលបានបោះពុម្ពផ្សាយ ដូចជាឈ្មោះពេញ ឈ្មោះសាលា ទីតាំងជាក់លាក់ ឬវត្ថុផ្ទាល់ខ្លួន (រួមបញ្ចូលគ្នា) នោះទេ។
- ប្រើតែរូបភាពរបស់កុមារដែលពាក់ព័ន្ធនឹងសកម្មភាព និងគម្រោងរបស់អង្គការ ដូចជាកុមារដែលចូលរួមក្នុងសកម្មភាព ដែលទាក់ទងជាមួយកម្មវិធីរបស់អង្គការ។
- ឳពុកម្តាយ/អាណាព្យាបាល (ហើយក្នុងករណីដែលអាចធ្វើបាន គឺកុមារ) ត្រូវបានផ្តល់ជម្រើសផ្តល់ ឬដកការយល់ព្រមមិនឱ្យកូនពួកគាត់ត្រូវបានថតរូប ឬថតសកម្មភាព ឬយករូបភាពទៅផ្សព្វផ្សាយ។ ការយល់ព្រមនឹងបន្ត ឬស្របតាមថេរវេលាកំណត់ដែលមានចែងនៅក្នុងទម្រង់យល់ព្រម លុះត្រាតែមានការដកចេញដោយមាតាបិតា/អាណាព្យាបាល ឬកុមារ។
- បើអាច ការអនុញ្ញាតិគឺត្រូវបានទទួលពីឳពុកម្តាយ/អាណាព្យាបាល (ហើយប្រសិនបើអាចធ្វើទៅបាន គឺពីកុមារ) សម្រាប់ការបោះពុម្ពផ្សាយរូបភាពដែលបង្ហាញកុមារជាក្រុម ដូចជានៅក្នុងថ្នាក់រៀន ឬនៅបរិវេណក្មេងលេង។
- គ្មានការទូទាត់ ឬសំណងជាទម្រង់ណាមួយត្រូវបានធ្វើឡើងចំពោះបុគ្គលណាម្នាក់ ឬឳពុកម្តាយ/អាណាព្យាបាលរបស់កុមារជាថ្នូរនឹងការអនុញ្ញាឱ្យថតរូប ឬវីដេអូរបស់ពួកគេឬ ចុះហត្ថលេខាព្រមឱ្យចេញផ្សព្វផ្សាយនោះឡើយ។
- មិនមានការប្រើរូបភាពរបស់កុមារពីប្រភពពាណិជ្ជកម្ម ឬប្រភពផ្សេងទៀត ដែលមិនមានឯកសារការអនុញ្ញាតច្បាស់លាស់ ពីឳពុកម្តាយ/អាណាព្យាបាលរបស់កុមារ ឬពីកុមារឡើយ។

ឈ. **អនុលោមភាព៖** អង្គការទស្សនៈឥតព្រំដែន នឹងអនុវត្តតាមគោលការណ៍ណែនាំអំពីផ្សាយអត្តសញ្ញាណអង្គការដែលផ្តល់ដោយម្ចាស់ជំនួយរបស់ខ្លួន។ ឧទាហរណ៍៖ នៅពេលទទួលបានមូលនិធិពីនាយកដ្ឋានកិច្ចការបរទេស និងពាណិជ្ជកម្មរបស់រដ្ឋាភិបាលអូស្ត្រាលី (DFAT) អង្គការទស្សនៈឥតព្រំដែននឹងគោរពតាមគោលការណ៍ណែនាំអំពីការផ្សាយអត្តសញ្ញាណអង្គការ ដែលបានផ្តល់ជូន។ អង្គការទស្សនៈឥតព្រំដែននឹងធានាថាធាតុកំណត់អត្តសញ្ញាណជំនួយអូស្ត្រាលីថ្មីៗបំផុត ត្រូវបានប្រើប្រាស់នៅរាល់សកម្មភាពពាក់ព័ន្ធ ដែលមាននិមិត្តសញ្ញាអង្គការទស្សនៈឥតព្រំដែន។ អង្គការទស្សនៈឥតព្រំដែន នឹងពិភាក្សាជាមួយប្រធានបេសកកម្ម ឬផ្នែកប្រាស្រ័យទាក់ទងនៅ DFAT ប្រសិនបើមានហេតុផលសំខាន់ ឬហានិភ័យសុវត្ថិភាព ដែលកំណត់បានអាចទាម

ទារការលើកលែងពីតម្រូវការនេះ។ អង្គការទស្សនៈឥតព្រំដែន នឹងធានាថាដៃគូអនុវត្តណាមួយ ដែលអង្គការអាចយល់ព្រមធ្វើការជាមួយក៏នឹងគោរពតាមគោលការណ៍ណែនាំទាំងនេះផងដែរ ប្រសិនបើកិច្ចសហការត្រូវបានបង្កើតឡើងនាពេលអនាគត។

៣. នៅពេលប្រាស្រ័យទាក់ទងជាមួយម្ចាស់ជំនួយ ឬម្ចាស់ជំនួយដែលមានសក្តានុពល វាជាការចាំបាច់ដើម្បីបង្ហាញតម្លាភាពពីរបៀបប្រើប្រាស់មូលនិធិរបស់ពួកគេ ដោយកំណត់ច្បាស់លាស់រវាងមូលនិធិដែលបានកំណត់ចំពោះ ឬមិនកំណត់ចំពោះ និងស្របតាមគោលការណ៍ដែលមានចែងក្នុងគោលនយោបាយរៃអង្គាសមូលនិធិ។ ដើម្បីផ្តល់ភាពច្បាស់លាស់បន្ថែមទៀត យើងបានពន្យល់ពីនិយមន័យរបស់នៃប្រភេទមូលនិធិទាំងពីរខាងក្រោមៈ

**មូលនិធិដែលបានកំណត់ចំពោះ** - មូលនិធិទាំងអស់ដែលបានបរិច្ចាគក្រោមកិច្ចសន្យាដែលកំណត់លើការប្រើប្រាស់។ ផលប៉ះពាល់នៃការប្រើប្រាស់ក្នុងដំណាក់កាលអនុវត្តមិនត្រូវបានធានាទេ លុះត្រាតែមានបញ្ជាក់នៅក្នុងឯកសារដែលបានចុះហត្ថលេខា។

**មូលនិធិដែលមិនបានកំណត់ចំពោះ** - មូលនិធិផ្តល់ជូននូវផ្នែកអ្វីក៏ដោយដែលអង្គការទស្សនៈឥតព្រំដែនជ្រើសរើស រួមទាំងនិងមិនកំណត់ចំពោះការចំណាយប្រតិបត្តិការ និងរដ្ឋបាលទូទៅ។

ក្នុងករណីដែលមូលនិធិ អាចត្រូវបានប្រើតាមតម្រូវការផ្សេងៗរបស់អង្គការទស្សនៈឥតព្រំដែន (ឧ. មូលនិធិដែលមិនបានកំណត់ចំពោះ) នឹងមិនមានការសន្យាជាក់លាក់ណាមួយ នឹងត្រូវបានធ្វើឡើងអំពីការប្រើប្រាស់មូលនិធិសម្រាប់សកម្មភាពជាក់លាក់ណាមួយឡើយ។ ផ្ទុយទៅវិញ ភាសាដែលបានប្រើនឹងបញ្ជាក់យ៉ាងច្បាស់ថា អង្គការនឹងបែងចែកមូលនិធិទៅកាន់តំបន់/សកម្មភាពដែលត្រូវការចាំបាច់បំផុត ដើម្បីធានាថាប្រតិបត្តិការត្រូវបានរក្សា និងអាចរីកចម្រើនដោយសារការបរិច្ចាគបែបនេះ។ តំណភ្ជាប់ទៅកាន់គេហទំព័រនឹងត្រូវបានផ្តល់ជូនសម្រាប់ព័ត៌មានលម្អិតអំពីសកម្មភាពផ្សេងៗ។ ម្ចាស់ជំនួយអាចទទួលបានកិច្ចព្រមព្រៀងគ្របដណ្តប់ចំណុចទាំងនេះតាមតម្រូវការ។ នៅក្នុងយុទ្ធនាការ ឬកម្មវិធីផ្តល់ជំនួយ គំរូនៃគម្រោង ឬសកម្មភាពអាចនឹងត្រូវបានប្រើប្រាស់ជាឧទាហរណ៍ ប៉ុន្តែគ្មានការធានានូវការប្រើប្រាស់ជាក់លាក់ទេ លុះត្រាតែម្ចាស់ជំនួយស្នើសុំវាយ៉ាងច្បាស់ អង្គការទស្សនៈឥតព្រំដែនចុះហត្ថលេខាលើកិច្ចព្រមព្រៀងទទួលស្គាល់ការទទួលខុសត្រូវរបស់ខ្លួននៅក្នុងករណីបែបនេះ។

## ៤.៣ ការឆ្លើយតបទៅនឹងការស្នើសុំព័ត៌មាន

សំណើរសាកសួរព័ត៌មានត្រូវបានបញ្ជូនទៅតំណាង ឬសមាជិកបុគ្គលិកអង្គការទស្សនៈឥតព្រំដែន ត្រឹមត្រូវទៅតាមមុខងារនិងតួនាទី។ នៅពេលឆ្លើយតបទៅនឹងសំណើព័ត៌មានជាក់លាក់ណាមួយ ហើយអ្នកប្រាស្រ័យទាក់ទងមិនប្រាកដអំពីភាពត្រឹមត្រូវនៃសេចក្តីថ្លែងការណ៍ ឬខ្វះព័ត៌មានចាំបាច់ បុគ្គលនោះត្រូវទទួលស្គាល់ និងបដិសេធមិនបញ្ចេញមតិ។ ផ្ទុយទៅវិញ ពួកគេនឹងបញ្ជូនរឿងនេះទៅបុគ្គលពាក់ព័ន្ធនៅក្នុងអង្គការទស្សនៈឥតព្រំដែន ។

អ្នកប្រាស្រ័យទាក់ទងក៏នឹងបដិសេធមិនធ្វើអត្ថាធិប្បាយនៅពេលដែលពួកគេត្រូវបានស្នើសុំយោបល់ ឬឱ្យធ្វើការប៉ាន់ស្មានលើលទ្ធផលណាមួយ លុះត្រាតែពួកគេត្រូវបានចាត់ចែងឲ្យទទួលខុសត្រូវរឿងនោះជាពិសេស ហើយមានការអនុញ្ញាតឱ្យផ្តល់យោបល់ពីបុគ្គលិកបង្គោល ឬក្រុមប្រឹក្សាភិបាល។

## ៤.៤ ការឆ្លើយសំណួរពីសារព័ត៌មាន

ការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយគឺជាទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងដំណាក់កាលដំបូង និងប្រគល់ឱ្យនាយកប្រតិបត្តិអន្តរជាតិ ឬបុគ្គលិកដែលត្រូវបានចាត់តាំងដោយនាយកប្រតិបត្តិ អន្តរជាតិ។ បុគ្គលិកម្នាក់ៗ មិនត្រូវបានអនុញ្ញាតឱ្យឆ្លើយសំណួរពី

ប្រព័ន្ធផ្សព្វផ្សាយលើប្រធានបទណាមួយឡើយ លុះត្រាតែជាផ្នែកមួយនៃយុទ្ធនាការជាក់លាក់មួយ ដែលត្រូវបានអនុម័តដោយបុគ្គលិកដែលបានចាត់តាំង។

## ៤.៥ ប្រាស្រ័យទាក់ទងទាក់ទងជាមួយអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត

ខ្លឹមសារបានបង្កប់នៅក្នុងគោលបំណងនៃគោលនយោបាយនេះ និងភ្ជាប់ជាមួយគុណតម្លៃរបស់អង្គការទស្សនៈឥតព្រំដែន រួចជាស្រេចហើយ ដែលត្រូវប្រើនៅពេលដែលយើងប្រាស្រ័យទាក់ទងជាមួយអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត។ ពេលខ្លះសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលផ្សេងទៀតហាក់ដូចជាពួកគេប្រកួតប្រជែងជាមួយយើង ឬខ្វះគោលបំណងតាមទស្សនវិជ្ជា ឬគុណតម្លៃរបស់អង្គការទស្សនៈឥតព្រំដែន។ ជាការសំខាន់ណាស់ ដែលយើងមិនប្រាស្រ័យទាក់ទងជាមួយស្ថាប័នបែបនេះ។ ផ្ទុយទៅវិញយើងគួរតែទទួលស្គាល់នូវសកម្មភាពដែលផ្តល់ផលជះវិជ្ជមានដែលស្ថាប័នផ្សេងទៀតកំពុងធ្វើជានិច្ច។ យើងប្រាស្រ័យទាក់ទងដោយគោរព និងមិនប្រមាថភ្នាក់ងារផ្សេងទៀត ឬថ្លែងការណ៍សាធារណៈមិនត្រឹមត្រូវ ឬបំភាន់ទាក់ទងនឹងការងាររបស់ពួកគេ ទោះជាក្រោមហេតុផលអ្វីក៏ដោយ ទោះជាយើងគិតថាវានឹងធ្វើលើកកេរ្តិ៍ឈ្មោះ ឬមានប្រយោជន៍ដល់អង្គការទស្សនៈឥតព្រំដែនក៏ដោយ។

## ៤.៦ របាយការណ៍ប្រចាំឆ្នាំ

អង្គការទស្សនៈឥតព្រំដែន នឹងប្រើប្រាស់របាយការណ៍ប្រចាំឆ្នាំ ជាផ្នែកសំខាន់នៃទំនួលខុសត្រូវរបស់ខ្លួនចំពោះភាគីពាក់ព័ន្ធទាំងអស់។ របាយការណ៍ប្រចាំឆ្នាំជាលាយលក្ខណ៍អក្សរ នឹងត្រូវបានផលិតដាក់ឱ្យប្រើប្រាស់ជាឯកសារដែលអាចទាញយកបានពីគេហទំព័រសម្រាប់អ្នកពាក់ព័ន្ធទាំងអស់រួមមានបុគ្គលិក អ្នកស្ម័គ្រចិត្ត អ្នកគាំទ្រ ភ្នាក់ងារដៃគូ និងសមាជិកសាធារណៈ។ អ្នកពាក់ព័ន្ធសំខាន់ៗ នឹងត្រូវបានជូនដំណឹងនៅពេលបោះពុម្ពរបាយការណ៍ប្រចាំឆ្នាំ។

របាយការណ៍ប្រចាំឆ្នាំនឹងផ្តល់ជូនភាគីពាក់ព័ន្ធជាមួយ៖

ក. ការពិពណ៌នាអំពីគោលបំណង វត្ថុបំណង គោលដៅ និងគុណតម្លៃរបស់អង្គការទស្សនៈឥតព្រំដែន
ខ. សេចក្តីសង្ខេបជាភាសាសាមញ្ញនៃចំណូល និងចំណាយ និងសុខុមាលភាពហិរញ្ញវត្ថុទាំងមូល
គ. ការពិពណ៌នាអំពីជំនួយ និងសកម្មភាពអភិវឌ្ឍន៍សំខាន់ៗបំផុត ដែលបានធ្វើឡើងក្នុងអំឡុងពេលរាយការណ៍ និងផលប៉ះពាល់/ផលប្រយោជន៍ និង
ឃ. ព័ត៌មានអំពីការវាយតម្លៃទៅលើប្រសិទ្ធភាព និងអ្វីដែលរៀនសូត្របានទទួលបានពីសកម្មភាពជំនួយ និងការអភិវឌ្ឍន៍ ដែលបានធ្វើ ឡើងក្នុងអំឡុងពេលនោះ។

របាយការណ៍ប្រចាំឆ្នាំក៏នឹងរួមបញ្ចូលជាពិសេសផងដែរ៖

ក. របាយការណ៍ពីអ្នកប្រធានគ្រប់គ្រង និង/ឬនាយក ឬក្រុមប្រឹក្សា
ខ. របាយការណ៍ហិរញ្ញវត្ថុ ចុំដែលរៀបចំដោយអនុលោមតាមតម្រូវការនៃតម្រូវការគណនេយ្យ និងបទប្បញ្ញត្តិពាក់ព័ន្ធទាំងអស់ រួមទាំងការណែនាំដូចមាននៅក្នុងក្រមប្រតិបត្តិ ACFID
គ. សេចក្តីថ្លែងការណ៍នៃការប្តេជ្ញប្រកាន់ខ្ជាប់ពេញលេញទៅរាល់ក្រមប្រតិបត្តិដែលពាក់ព័ន្ធ រួមទាំងក្រមប្រតិបត្តិ ACFID
ឃ. ការទទួលស្គាល់ជម្រើសក្នុងការដាក់ពាក្យបណ្តឹងប្រឆាំងនឹងអង្គការទស្សនៈឥតព្រំដែន និងរបៀបទំនាក់ទំនងទៅអ្នកទទួលខុសត្រូវលើផ្នែកនេះ។ និង
ង. ការទទួលស្គាល់ជម្រើសក្នុងការដាក់ពាក្យបណ្តឹងអំពីការរំលោភលើក្រមប្រតិបត្តិ ACFID ទៅគណៈកម្មាធិការក្រមប្រតិបត្តិ ACFID រួមជាមួយនឹងអ្នកទទួលខុសត្រូវលើផ្នែកនេះ។

## ៤.៧ របាយការណ៍ហិរញ្ញវត្ថុ

ដោយអនុលោមតាមលក្ខខណ្ឌតម្រូវនៃក្រមប្រតិបត្តិ ACFID អង្គការទស្សនៈឥតព្រំដែន នឹងបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់រួមមាន៖

ក. របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងស្របតាមការប្តេជ្ញាចិត្តទី៨ នៃក្រមប្រតិបត្តិ ACFID និងភ្ជាប់ជាមួយនិយមន័យហិរញ្ញវត្ថុ។ តម្រូវការនេះនឹងត្រូវបំពេញ បើទោះជាវាមិនត្រូវបានចាប់បង្ខំអនុវត្តដោយច្បាប់ណាមួយឡើយ។

ខ. ប្រើរបាយការណ៍ហិរញ្ញវត្ថុពេញលេញជាឯកសារយោង ដែលអាចរកបានក្នុងករណី ដែលវាមិនត្រូវបានបញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំ។

គ. របាយការណ៍សវនកម្មលើរបាយការណ៍សង្ខេបហិរញ្ញវត្ថុនៃក្រមប្រតិបត្តិ ACFID ឬរបាយការណ៍ហិរញ្ញវត្ថុទាំងមូលត្រូវបានបញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំដែលទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុពេញលេញ។

អង្គការទស្សនៈឥតព្រំដែន នឹងធ្វើឱ្យប្រាកដថាការបរិយាយអំពីដំណើរការហិរញ្ញវត្ថុ មានបញ្ជាក់ឲ្យអ្នកពាក់ព័ន្ធដឹងថាពួកគេមានសិទ្ធអាចមើលរបាយការណ៍ហិរញ្ញវត្ថុពេញបាន។ វាស្របនឹងក្រមប្រតិបត្តិ ACFID (ការប្តេជ្ញាចិត្តទី ៨.៣) ដែលអង្គការទស្សនៈឥតព្រំដែននឹងអនុវត្តតាម ហើយវារួមបញ្ចូល៖

១. ប្រសិនបើអង្គការទស្សនៈឥតព្រំដែនរួមបញ្ចូលតែក្រមប្រតិបត្តិនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេប នៅក្នុងរបាយការណ៍ប្រចាំឆ្នាំនោះវានឹងបញ្ជាក់យ៉ាងច្បាស់ថារបាយការណ៍ហិរញ្ញវត្ថុពេញលេញអាចទទួលបានតាមការស្នើសុំ។

២. ការបោះពុម្ពផ្សាយបន្ថែមណាមួយដែលនិយាយអំពីដំណើរការហិរញ្ញវត្ថុ ការសង្ខេប ដកស្រង់លម្អិត ឬអត្ថាធិប្បាយទេ នោះបញ្ជាក់យ៉ាងច្បាស់ថា អាចស្នើសុំរបាយការណ៍ហិរញ្ញវត្ថុពេញលេញបាន។

## ៤.៨ អ្វីដែលរៀនសូត្របាន

ចាប់ពីឆ្នាំ ២០១៦ អង្គការទស្សនៈឥតព្រំដែនបានបោះពុម្ពផ្សាយជាប្រចាំនូវរបាយការណ៍អ្វីដែលរៀនសូត្របាន (ពីមុនត្រូវបានហៅថាជារបាយការណ៍តម្លាភាព)។ របាយការណ៍នេះបង្ហាញពីសមិទ្ធិផលសំខាន់ៗ ប្រសិទ្ធភាពរបស់យើង និងមេរៀនដ៏មានតម្លៃដែលយើងទទួលបាន។ សម្រាប់ផ្នែកការងារនីមួយៗ យើងរៀបបញ្ហាប្រឈមដែលយើងជួបប្រទះជាមួយការផ្លាស់ប្តូរ ដែលយើងនឹងអនុវត្តដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ។

## ៥. ការគ្រប់គ្រងគោលនយោបាយ

គោលនយោបាយនេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលអូស្រ្តាលី និងអ្នកទទួលខុសត្រូវនៃអង្គភាពផ្សេងទៀតរបស់អង្គការទស្សនៈឥតព្រំដែនដូចដែលបានកត់សម្គាល់ខាងក្រោម។

ការធ្វើវិសោធនកម្ម និងការវិវឌ្ឍន៍នឹងត្រូវបានស្នើដល់ក្រុមប្រឹក្សាភិបាលតាមភាពចាំបាច់តាមរយៈថ្នាក់ដឹកនាំជាន់ខ្ពស់។ ការពិនិត្យឡើងវិញជាផ្លូវការនឹងត្រូវធ្វើឡើង មុនពេលកំណត់រយៈពេល ៣ ឆ្នាំ ចាប់ពីថ្ងៃគម្រប់ខួបនៃការអនុម័តដោយក្រុមប្រឹក្សាភិបាល។ អនុសាសន៍សម្រាប់ការផ្លាស់ប្តូរតូចតាច អាចត្រូវបានយល់ព្រមដោយនាយកប្រតិបត្តិ មុនពេលផុតកំណត់រយៈពេល ៣ ឆ្នាំ ហើយអនុសាសន៍សម្រាប់ការផ្លាស់ប្តូរសារវ័តា ឬកិច្ចប្រតិបត្តិគោលនយោបាយ អាចត្រូវបាន អនុម័តដោយអនុគណៈកម្មាធិការដែលពាក់ព័ន្ធ។

| Doc ref | Doc type | Approved by Australian Board Date | Minute Ref | Approved by UK trustees Date | Minute ref | Approved by Irish Board Date | Minute Ref |
|---|---|---|---|---|---|---|---|
| | Policy Review | Board<br>Nov 2019 | | | | N/A | N/A |
| ComP/11/2019/2.0 | Minor amendments | N/A – approved by CEO | IN/A – approved by CEO | N/A – approved by CEO | N/A – approved by CEO | N/A – approved by CEO | N/A – approved by CEO |
| ComP/11/2022/3.0 | Policy Review | Board<br>Dec 2022 | Minute, Board December 5, 2022 | N/A | N/A | N/A | N/A |
| | | | | | | | |